សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ វិជ្ជាសម្បត្តិ និងចរិយាសម្បត្តិ

**Website: www.hoksavann.org**

ថ្ងៃទី២២ ធ្នូ ២០០៩



វិជ្ជាសម្បត្តិនិងចរិយាសម្បត្តិទាំងពីរនេះ ជាគុណធម៌របស់មនុស្ស ។ វិជ្ជាសម្បត្តិប្រែថា ការមានវិជ្ជា ។ ចរិយាសម្បត្តិប្រែថា ការមានចរិយាល្អ ។ គុណធម៌ទាំងពីរនេះតែងមានទំនាក់ទំនងគ្នា ចោលគ្នាមិនបាន ដើម្បីឲ្យមនុស្សម្នាក់ៗមានតម្លៃថ្លៃថ្នូរនិងខ្ពង់ខ្ពស់ ។ មនុស្សមានវិជ្ជាសម្បត្តិចាំបាច់សំរាប់បំភ្លឺផ្លូវមនុស្សឲ្យដើរផ្លូវត្រូវ ដើម្បីសេចក្តីសុខចំរើន ។ ប៉ុន្តែបើមនុស្សមានវិជ្ជាជ្រៅជ្រះយ៉ាងណាក៏ដោយ បើពុំមានចរិយាល្អទេ មនុស្សនោះពុំមានតម្លៃអ្វីឡើយ ។ ចំណែកមនុស្សមានចរិយាល្អជាគុណធម៌មួយហើយ ប៉ុន្តែបើគ្មានវិជ្ជាសំរាប់ជួយបំភ្លឺផ្លូវផងទេ ថ្ងៃណាមួយអាចប្រព្រឹត្តខុសទៅជាមានចរិយាអាក្រក់ ជាចរិយាវិបត្តិទៅវិញ ។ វិជ្ជាសម្បត្តិទុកដូចជាផែនទីបំភ្លឺផ្លូវ ឯចរិយាសម្បត្តិគឺការដើរតាមផែនទីដែលបំភ្លឺផ្លូវនោះ ។ ចំពោះលក្ខណៈនៃវិជ្ជាដែលទុកដូចជាផែនទីបំភ្លឺផ្លូវនោះ គឺវិជ្ជាល្អត្រឹមត្រូវ វិជ្ជាបង្ហាញផ្លូវទៅរកសុខចំរើន ។ ពុំមែនជាវិជ្ជានាំទៅរកសេចក្តីទុក្ខ ដូចជាវិជ្ជាបង្ហាញផ្លូវធ្វើចោរប្លន់ វិជ្ជាជួញដូរគ្រឿងស្រវឹង គ្រឿងញៀន វិជ្ជាផលិតនិងលក់គ្រឿងសាស្ត្រាវុធ វិជ្ជាជួញដូរមនុស្សជាដើម ដែលជាវិជ្ជាខុសផ្លូវលោកផ្លូវធម៌ ពុំត្រូវតាមន័យក្នុងវិជ្ជាសម្បត្តិនោះឡើយ ។

វិជ្ជាក្នុងទីនេះសំដៅយកវិជ្ជាទាំងផ្លូវលោកទាំងផ្លូវធម៌ ។ វិជ្ជាផ្លូវលោក គឺវិជ្ជាលោកនិយមសំរាប់ជាវិជ្ជាជីវៈ ធ្វើការរកស៊ីចិញ្ចឹមជីវិតតាមជំនាញផ្សេងៗ ។ ទន្ទឹមគ្នានោះ ត្រូវរៀនវិជ្ជាច្បាប់ទម្លាប់របស់ប្រទេសដូចជាច្បាប់រដ្ឋធម្មនុញ្ញ ជាច្បាប់កំពូលរបស់ជាតិ ដើម្បីការចេះដឹងសម្រួលដល់ការអនុវត្តន៍ច្បាប់ ។ ទំនៀមទំលាប់ប្រពៃណីនិងបុណ្យជាតិផ្សេងៗ ក៏ត្រូវសិក្សាឲ្យយល់អត្ថន័យច្បាស់ ដើម្បីសម្របខ្លួនឲ្យស្របតាមលក្ខណៈសង្គមខ្មែរ និងស្របតាមអត្តសញ្ញាណជាតិ ។

ដោយប្រទេសកម្ពុជា ប្រជាពលរដ្ឋខ្មែរចំនួន៩៥%ជាអ្នកគោរពព្រះពុទ្ធសាសនា ដូច្នេះវិជ្ជាផ្លូវធម៌ជាវិជ្ជាចាំបាច់ដែលត្រូវសិក្សាឲ្យយល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធឲ្យបានច្បាស់លាស់ ទុកជាពន្លឺសំរាប់បំភ្លឺការប្រតិបត្តិឲ្យបានត្រឹមត្រូវតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។ ការប្រៀនប្រដៅឲ្យធ្វើល្អតាមផ្លូវកាយនិងវាចាជាផ្នែកសីល វិធីហ្វឹកហាត់ឲ្យចិត្តស្ងប់រម្ងាប់ជាផ្នែកសមាធិ វិធីពិចារណារូបរាងកាយចិត្តវិញ្ញាណរបស់មនុស្សសត្វឲ្យឃើញការពិតថា ពុំទៀងជាទុក្ខ ពុំមែនខ្លួនប្រាណជាផ្នែកបញ្ញា ឬហៅថាវិបស្សនា ។

ពុទ្ធសាសនិកជនខ្មែរប្រតិបត្តិព្រះពុទ្ធសាសនាមានពីរប្រភេទ គ្រហស្ថអ្នកនៅគ្រប់គ្រងផ្ទះមានប្តីប្រពន្ធកូនចៅរកស៊ីធ្វើការងារចិញ្ចឹមជីវិតដោយខ្លួនឯង ធ្វើទានរក្សាសីលចំរើនមេត្តាភាវនាជាផ្នែកមួយ ។ ផ្នែកមួយទៀត បានដល់បព្វជិត គឺព្រះសង្ឃអ្នកបួសលះបង់ផ្ទះសំបែងរស់នៅក្នុងទីមួយ ដែលហៅថាវត្ត ។ ជីវិតរបស់ព្រះសង្ឃរស់នៅដោយការប្រគេនបច្ច័យ៤មានចីវរបច្ច័យជាដើមពីពុទ្ធបរិស័ទជាគ្រហស្ថដោយសទ្ធាជ្រះថ្លា ។ ព្រះសង្ឃមានភារកិច្ចសិក្សាធម៌វិន័យរបស់ព្រះពុទ្ធឲ្យយល់ច្បាស់លាស់ ហើយប្រតិបត្តិតាមឲ្យបានត្រឹមត្រូវ ។ មុខងារមួយទៀត ព្រះសង្ឃគប្បីបង្ហាត់បង្រៀនទេសនាពន្យល់ធម៌របស់គ្រហស្ថ មានឲ្យរក្សាសីល៥ រកស៊ីចិញ្ចឹមជីវិតប្រកបដោយធម៌សុចរិតជាដើម ដល់ពុទ្ធបរិស័ទ ។

ដើម្បីឲ្យមនុស្សមានតម្លៃខ្ពង់ខ្ពស់ថ្លៃថ្នូរ ត្រូវមានវិជ្ជាសម្បត្តិនិងចរិយាសម្បត្តិទាំងពីរនេះឯង ។ វិជ្ជាជាមរតកស្ថិតនៅក្នុងខ្លួនចោរលួចមិនបាន ភ្លើងមិនអាចឆេះបាន ជាពន្លឺរបស់ជីវិត ។ ពន្លឺរបស់ព្រះច័ន្ទភ្លឺបានតែពេលយប់ ពន្លឺព្រះអាទិត្យភ្លឺបានតែពេលថ្ងៃ ចំណែកពន្លឺវិជ្ជាឬពន្លឺបញ្ញាជាពន្លឺភ្លឺសព្វ អាចដោះស្រាយបញ្ហាដែលចោទឡើងក្នុងជីវិត ។ ចរិយាសម្បត្តិជាគុណធម៌របស់មនុស្ស ។ កាលណាមនុស្សប្រព្រឹត្តល្អ ឈ្មោះថាមិនបង្កើតសេចក្តីទុក្ខឲ្យដល់អ្នកដទៃ ហើយការប្រព្រឹត្តល្អនេះអាចជួយឲ្យអ្នកដទៃបានសេចក្តីសុខ ។

ការបណ្តុះវិជ្ជាសម្បត្តិនិងចរិយាសម្បត្តិឲ្យកើតមានដល់យុវជននិងយុវនារីខ្មែរ ជាការបណ្តុះធនធានមនុស្សឲ្យមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីទ្រទ្រង់ជាតិឲ្យលូតលាស់ចំរើន ។ បានសេចក្តីថា ប្រទេសណាមានអ្នកចេះដឹងច្រើន ប្រទេសនោះមានការលូតលាស់ចំរើន ដោយអ្នកចេះដឹងតែងមានការប៉ិនប្រសប់ស្ទាត់ជំនាញដឹងហេតុដែលនាំឲ្យវិនាស និងហេតុដែលនាំឲ្យមានសេចក្តីចំរើន ហើយអនុវត្តតែផ្លូវដែលនាំឲ្យមានសុខសន្តិភាព និងលូតលាស់ចំរើន ។៚

❄ ❄

❄